# វេទិកាគ្រូបង្រៀន

នៅថ្ងៃទី ២៣-២៤ ខែ ឧសភា ឆ្នាំ ២០០៩ អង្គការ សេដាក បានរៀបចំ វេទិកាគ្រូបង្រៀនមួយ នៅការិយាល័យអង្គការ សេដាក នៅស្រុកបាភ្នំ និងស្រុកព្រះស្តេច ខេត្តព្រៃវែង និងនៅសាលាអនុវិទ្យាល័យល្វា ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ វេទិកានេះមានអ្នកចូលរួមចំនួនប្រមាណព ៥០ នាក់ក្នុងមួយវគ្គ មកពីសាលាផ្សេងៗក្នុងស្រុកបាភ្នំ និងស្រុកព្រះស្តេច ខេត្តព្រៃវែង និងស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

វេទិកានេះ រៀបចំឡើងក្នុងគោលបំណងដូចខាងក្រោមយ:

- ផ្តល់ឱកាសអោយលោកគ្រូ-អ្នកគ្រូ និងថ្នាក់ដឹកនាំសាលាពិភាក្សា និងផ្លាស់ប្តូរពិសោធន៍ជុំវិញ ការងារអប់រំ ការងារបង្កបង្កើនផល ក៏ដូចជាការងារអភិវឌ្ឍន៍
- ផ្លាស់ប្តូរបទពិសោធន៍ រវាងកសិករគំរូ សហការជាមួយ សេដាក និងគ្រូបង្រៀន
- ផ្លាស់ប្តូរបទពិសោធន៍ លើការងារដឹកនាំក្រុមសន្សំប្រាក់ដើម្បីភាពអាស្រ័យលើខ្លួនឯង រវាង សេដាក និងលោកគ្រូ-អ្នកគ្រូ

កម្មវិធីវេទិកានេះ ត្រូវបានឧបត្ថម្ភដោយសហគមន៍អឺរ៉ុប និងមូលនិធិ ហ្វ្រីឌ្រិចណៅម៉ាន់ នៃប្រទេសអាល្លឺម៉ង់ តាមរយ:គំរោង "ការគ្រប់គ្រងសហគមន៍ និងកសាងសមត្ថភាពដើម្បីភាពអាស្រ័យលើខ្លួនឯង ដើម្បីរួមចំណែកការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា" ។

គួរបញ្ជាក់ថា តាមរយ:គំរោងនេះ ចាប់តាំងពីឆ្នាំ ២០០៧ មក អង្គការ សេដាក បាន និងកំពុងសហការរៀបចំវេទិកាគ្រូបង្រៀន នៅតាមបណ្តាខេត្ត ចំនួន ៩ រួមមាន: ខេត្តព្រៃវែង កំពង់ធំ កំពង់ចាម ស្វាយរៀង តាកែវ កំពត កំពង់ឆ្នាំង សៀមរាប ពោធិ៍សាត់ និងរាជធានីភ្នំពេញ។